# ពាក្យពេចន៍ខ្លះគួរពិចារណា

## សម្រង់ចាកសៀវភៅប្រមូលភាសិតខ្មែរ

### ស្រាវជ្រាវ ចងក្រង និង ចេញផ្សាយដោយ៖ **សមាគមសម្ដេច ជួន ណាត**

១. ម៉ែឪមានគុណណាស់  មិនសំពះខ្មាសអៀនដៃ  រីអ្នកក្រៅសុទ្ធវិស័យ  បែរលើកដៃសំពះបាន។

២. ម៉ែឪនៅផ្ទះ  លោកទុកដូចព្រះនៅឯវត្ត  សំពត់អាហារត្រូវកូនផ្គង់ផ្គត់  កុំឱ្យលោកអត់  បានបុណ្យដូចគ្នា។

៣. ទ្បើងទ្រើងដូចឃ្លោកដូចត្រឡាច  គ្មានកោតគ្មានខ្លាចបុគ្គលណា  ដល់ទ្រើងរលំដួលផ្កាប់ផ្ងារ  ធ្វើមុខដូចស្វាហៅគេជួយ។

៤. ឃើញគេបានថ្កុំថ្កើង  កុំចបើងចង់តាមគេ  ឱ្យហួសមាឌខ្លួនទេ  តែកុំចោលក្ដីព្យាយាម។

៥. រស់នៅអសារ  អ្នកប្រាជ្ញលោកថា  មិនគាប់ប្រពៃ  លុះតែប្រឹងប្រែង  ទុកកេរ្តិ៍ស្នាដៃ  ទុកប្រាជ្ញាថ្លៃ
ទើបរស់បានផល។

៥. យូរអ្វីមិនស្មើចិត្តដែលនឹក  ខ្លាំងអ្វីមិនស្មើទឹកជំនន់  ធ្ងន់អ្វីមិនស្មើនឹងព្រះគុណ  ធន់អ្វីមិនស្មើប្រពន្ធប្រើ។

៦. រីនឹងចេះឯង  ដូចអ្នកវង្វេងកណ្ដាលអធ្វា  ពុំនោះដូចខ្វាក់  តែម្នាក់អាត្មា  ចរចេញយាត្រា  ឥតអ្នកដឹកដៃ។

៧. រីទ្រព្យសម្បត្តិ  ត្រូវតែប្រយ័ត្ន  កុំឱ្យអន្តរាយ  បានច្រើនចាយតិច  កុំឱ្យខ្ជះខ្ជាយ  តែចាយពាយងាយ
ធ្លាក់ខ្លួនក្រក្រី។

៨. រូបរាងសខ្មៅ  លោកមិនសំដៅ  យកជាប្រមាណ  ប៉ុន្តែឯចិត្ត  ជាដួងវិញ្ញាណ  ល្អក្រៃរកបាន  ទើបគាប់ប្រសើរ។

៩. រៀនស៊ីឱ្យល្មមកុំពមល្មោភ  កុំលេបរំលោភបួកដូចប្រេត  តែស៊ីច្រើនពេកច្រើនកើតហេតុ  ស៊ីហួសពីឆ្អែតបង់អាត្មា។

១០. រៀនច្បាប់ឱ្យឆ្អិនកុំឱ្យឆៅ  ចេះល្អិតក្នុងក្រៅអ្នកខ្លៅខ្លាច  មនុស្សមានចំណេះមានអំណាច  ចង់ឈ្នះមនុស្សកាច
កុំស្ដីកោង។

១១. រោគឃ្លាននាំមនុស្សហ៊ានលួចប្លន់  ស្រលាញ់ពេកពន់ហ៊ានចាក់កាប់។

១២. មានរោគត្រូវមានឱសថកែ  កើតទុក្ខចិត្តប្រែធម៌ជាថ្នាំ  ពេលក្រលំបាកខន្តីទ្រាំ  ចិត្តពាលប្រាជ្ញផ្ដាំគ្មានថ្នាំកែ។

១៣. ឫស្សីមួយដើមមានច្រើនថ្នាំង   បងប្អូនត្រឡាំងមានច្រើនចិត្ត។

១៤. ឫស្សីធ្វើភ្លាក់ដាក់គ្មានថ្នាំង (ភ្លាក់ = បំពង់មានគម្រប សម្រាប់ច្រកសរពើវត្ថុទាំងពួង : ភ្លាក់បារី, ភ្លាក់ទៀន, ភ្លាក់ម្ជុល) គងស្គរគាំងវាយមិនឮ  សុរិយាមិនយកជាពន្លឺ  អួតភ្លឺអំពិលអំពែកសត្វ។

១៥. ឫស្សីអាងបន្លាការពារខ្លួន   ប្រាជ្ញអាងច្បាប់ក្បួនការពារខុស  មនុស្សល្ងង់គ្មានអ្វីអាងទាំងអស់ អាងតទល់ឈ្លោះកម្លាំងបាយ។

១៦. លិចសឹមលោត  ដល់គម្លោតសឹមតោង។

១៧. ឮផ្គរឱ្យមើលខ្យល់   ក្ដីពុំយល់កុំអាលក្រោធ។

១៨. ល្មមទៅល្មមខាន  ល្មមដើរបំពាន  ពុំគិតក្រងាយ  ល្មមឈប់បង្អង់  ល្មមខាននៅអាយ  ក្ដីក្រកុំស្រាយ ក្ដីងាយកុំធ្វេស។

១៩. វាចាត្រជាក់ មិត្រជុំចម្រើននៅ  វាចាក្ដៅ មិត្រឃ្លាតប្រាសចាកមិត្រ  ត្រជាក់ក្ដៅដូចព្រះច័ន្ទនិងព្រះអាទិត្យ ហៃបណ្ឌិតគួរដឹងដោយឧបមា។

២០. វិជ្ជាមិនដែលកើតឡើងឯង  ដល់អ្នកមិនស្វែងខំសិក្សា  ទ្រព្យធនមិនដែលកើតដល់នរណា  ដែលគ្មានឧស្សាហ៍សន្សំរក។

២១. វិជ្ជានិងវ័យមនុស្ស  មិនត្រូវឱ្យខុសជំនាន់គ្នា  វ័យច្រើនត្រូវចម្រើនដោយវិជ្ជា  ទាំងពីរស្មើគ្នាទើបប្រពៃ។

២២. វិស័យចេះច្រើនលំបាកគេច  ចេះតិចព្រួយប្រាណរំខានគិត។

២៣. វិស័យបុគ្គលមានឧបាយ  កែកុននាយអាយកាយត្រលប់  ធ្វើការបានស្អាតល្អទាំងគ្រប់ ធាប់កើតធាប់ចប់មិនបាច់ព្រួយ។

២៤. វែងផុតត្រឹមពាក្យសម្ដី  ខ្លីផុតត្រឹមមិននិយាយ។

២៥. សង់ផ្ទះតាមចិត្តអ្នកនៅ។

២៦. សិស្សប្រាជ្ញជ្បិតគ្រូនាំស្វាធ្យាយ  កូនជាជ្បិតម្ដាយឪពុកប្រដៅ។

២៧. សព្វមន្តទាំងឡាយ  ពុំបានស្វាធ្យាយ  ជាមន្ទិលប្រាជ្ញា  វីទីគ្រឹះស្ថាន  ពុំបានរក្សា  ថៃទាំប្រក់ណា ជាមន្ទិលលំនៅ។

២៨. សមុទ្រដលស័យមានជោរនាច ផ្លែឈើអាចមានទុំស្រគាល ដួងច័ន្ទជួនអាប់ជួនភ្លឺច្រាល នេះឯងបណ្តាលពីអនិច្ចំ។

២៩. សត្វស្មោញគួរត្រាប់ លោកទុកជាច្បាប់សណ្តាប់អាត្មា កុំត្រាប់ជ្រូកស្រុកនៅក្នុងទ្រុងមារ ដល់ពេលប្រហារ ទើបដឹងខ្លួនស្លាប់។

៣០. សត្វទាំងឡាយទោះកាយតូចល្អិតយ៉ាងណា អាចរក្សាការជីវិតឱ្យរស់បាន មនុស្សក្រខ្សត់គោកយ៉ាកយ៉ាប់អាប់ប៉ុន្មាន កុំគិតស្មានថាមិនចេះយោងជីវិត។

៣១. សន្តានមាតាបិតា អាក្រក់ល្អយ៉ាងណា កូនតែងតែដើរទៅតាមលំអាន ដូចកលផ្លែឈើ ជ្រុះចុះពីលើ ទើរជិតគល់វា។

៣២. សប្បាយនឹងល្បែង ហេងស៊ែយចង់លេង ផ្សងព្រេងវាសនា នឹងកើតទុក្ខក្រោយ នឹងអស់ទ្រព្យា នឹងកើតនិន្ទា បង់មារយាទគាប់។
សប្បាយធ្វើស្រែ ចម្ការជ្រួញប្រែ នោះមានគេរាប់ សប្បាយបានស៊ី សប្បាយបានទ្រព្យ សប្បាយនោះគាប់ សប្បាយយឺនយូរ។

៣៣. អ្នកណាមានគេសរសើរ អ្នកនោះឯងក៏តែងមានគេនិន្ទា។

៣៤. សប្បុរសពេកចាញ់ធន នាទុជំនចាញ់ឥន្ទ្រីយ៍ ប្រពន្ធល្អច្រើនចាញ់ប្តី ពាក្យអប្រិយចាញ់អាត្មា។

៣៥. សប្បុរសយល់ដោយមុខ ស៊ុកគ្រលុកពេកពុំជា (ស៊ុកគ្រលុក = ដែលច្របូកច្របល់; ខ្ជីខ្ជា, ឥតសណ្តាប់ធ្នាប់; កញ្ជះកញ្ជាយ) កំណាញ់ក្រៅតម្រា សោតសឹងអាប់ប្រយោជន៍យស។

៣៦. សម្លមិនឆ្ងាញ់ឱ្យតែនៅក្តៅ ប្រពន្ធខ្មៅឱ្យតែនៅក្មេង។

៣៧. សរសើរបាយកាលបាយរលាយជ្រាប សរសើរមិត្រកាលស្ថិតក្នុងភាពលង់អជិក។

៣៨. សរសើរពេលត្រូវការ ទុកដូចឆ្មារចាំកណ្តុរ សរសើរពេលវិលចាកប្រាបសឹក ដូចសរសើរពេលដឹកស្រូវមកផ្ទះ។

៣៩. ស៊ីច្រើន ច្រើនជុះ លេងច្រើន ច្រើនឈ្លោះ ដេកច្រើន ច្រើនខ្ជិល។

៤០. ស៊ីបាយនឹងពន្លឺទៀន និយាយនឹងមនុស្សមានរបៀនសប្បាយស្តាប់។

៤២. ស៊ីបាយនឹងត្រលោក ផឹកទឹកនឹងលលាដ៍ កុំអាលសើចគ្នា ផ្គរលាន់ម្តងម្នាក់។

៤៣. បាចអង្គាមបញ្ច្រាសខ្យល់ និយាយនឹងកំហល់ ប៉ុនគេយកអង្រៃបុកកណ្តាលដើមទ្រូង។

៤៤. សូវឱ្យក្រពើលេប កុំឱ្យច្រវាប្រឫិច សូវឱ្យសាច់ កុំប្រាប់ឱ្យស្គាល់ព្រៃ។

៤៥. រទេះបាក់មិនគិត ទៅគិតឯគោលូចដាំង (ការធំមិនគិត ទៅគិតឯការតូចតាចឥតបានជាប្រយោជន៍អ្វី)។

៤៦. សូវបែកក្បាល កុំឱ្យបែកឆ្នាំង សូវដាច់ចង្កាដាំង កុំឱ្យស្រីមើលងាយ
(ដាំង = អង្គជាតិរបស់បុរសឬសត្វឈ្មោល)។

៤៧. សូវស្តួចកុំឱ្យដាច់ បើឃើញតិចឱ្យឧស្សាហ៍ រិះរកផ្សំទៀតណា ឱ្យបានច្រើនក្រវើនទុក។

៤៨. សូវស្លាប់បា កុំឱ្យស្លាប់មេ សូវលិចទូកកណ្តាលទន្លេ កុំឱ្យភ្លើងឆេះផ្ទះ។

៤៩. ស៊ូធ្វើសង្គ្រាមទើបជាតិនាមល្បី ស៊ូចុះចាញ់ស្រីទើបក្តីស្ងប់ស្ងាត់ ស៊ូប្រឹងធ្វើការទើបស្ថាពរអត្ត
ស៊ូប្រតិបត្តិទើបខ្ជាត់មន្ទិល។

៥០. សេះជាឱ្យស្ទុះមើលកម្លាំង គោខ្លាំងឱ្យផ្ទុកធ្ងន់បរមើលវា មេធាឱ្យស្តាប់ស័ព្ទនិយាយ (មេធា = អ្នកប្រាជ្ញ
ឬអ្នកមានគំនិត)។

៥១. សម្តីពោលចេញ មិនអាចលេបវិញ បាត់ស្ងាត់ឡើយណា ហេតុនេះត្រូវប្រុង ប្រយ័ត្នអាត្មា កុំឱ្យចរចារ
ថ្លស់ឆ្លោយជាប់កុន។

៥២. សម្តីជាឯក លេខជាទោ អក្សរជាត្រី (ចេះសម្តីទុកជាទី១ ចេះវិជ្ជាលេខទុកជាទី២ ចេះសរសេរអក្សរល្អជាទី៣ គឺការ
ពូកែសម្តីប្រសើរជាងការពូកែវិជ្ជាលេខនិងការពូកែសរសេរអក្សរល្អ)។

៥៣. សម្តីសជាតិ មារយាទសពូជ (សំនៀងភាសា ប្រាប់ឱ្យគេស្គាល់ពីជាតិសាសន៍ ឫកពារមារយាទ ប្រាប់ឱ្យគេស្គាល់ពូជ
ពង្សវង់ត្រកូល)។

៥៤. សំពៅពឹងព្រះពាយ អ្នកអភិប្រាយពឹងវាចា។

៥៥. ស្គាល់ឈ្លាសឬល្ងង់ ស្គាល់វៀចឬត្រង់ ដោយការចរចា។

៥៦. ស្គាល់ចិត្តប្រុសស្រី អាក្រក់ល្អក្តី ចេញពីដួងនេត្រ ប្រាប់សុខទុក្ខផង បើយើងសង្កេត គង់ដឹងហេតុភេទ
ដួងនេត្របញ្ជាក់។

៥៧. ស្តីការមុខក្រោយឱ្យគិតភ្លាត់ កុំអាងតែមាត់មានប្រហោង បើមនុស្សព្រហើនមិនទំនង
កុំកោងតទល់កើតទោសទាស់។

៥៨. ស្តេចមិនត្រិះពិនិត្យ  ធ្វើតាមចិត្តមិនឧត្តម  បណ្ឌិតខឹងមិនសម  មិនឧត្តមតាមជាតិប្រាជ្ញ។

៥៩. ស្តេចកបដោយទសធម៌  ជាលម្អនៃផែនដី  វិជ្ជាកបប្រពៃ  ជាលម្អនៃអស់មនុស្ស។

៦០. ស្រលាញ់ណាស់ប្រែស្អប់  បុត្រល្អសំណព្វថ្នមហួសខូចខុស  ស្រលាញ់ភរិយាប្រច័ណ្ឌសាយសុស  ស្រីដែលស្អប់ប្រុសច្រើនធាប់បានប្តី។

៦១. ស្រលាញ់ពេញប្រាស  ស្អប់ណាស់ជំពប់លើ។

៦២. ស្រលាញ់ផ្លែ  ឱ្យថៃគល់។

៦៣. ស្រលាញ់កុំទៅញឹកៗ  រឭកសឹមទៅម្តងៗ។

៦៤. ស្រីឯណាមានទុកិរិយាទាំងប្រាំ  ប្រុសត្រូវចាំចំណាំទុកក្នុងចិន្តា  គឺមារយាទពោលនាំពាក្យឫស្យា
តែងអាត្មាចង់ឱ្យប្រុសគន់មេត្រី។  ត្រេចយាត្រាដើរលេងតាមផ្ទះគេ  មិនរិះរឿងដាំស្លប្រចាំប្តី
ស៊ីបាយមុនពុំគិតដល់ស្វាមី  ស្រីយ៉ាងនោះ ទោះមានកូនជប់ក្តីគប្បីលែង។

៦៥. បុរសណាមានទុកិរិយាទាំងប្រាំ  ស្ត្រីត្រូវចាំកុំយកជាប្តីណា  គឺមានឫកប្រមឹកខាងសុរា  ត្រេចលេលាដើរលេង
គ្មានការងារ។  គប់បាបមិត្រមានចិត្តជាអ្នកលេង  ងប់នឹងល្បែងភ្នាល់ជល់និងប៉ោបៀ  ខ្ជិលច្រអូសស្រមូសគ្មានវិជ្ជា
យកធ្វើប្តីនាំវេទនាអំពល់ប្រាណ។

៦៦. កុំស្រើបតាមផ្គរ  កុំអរតាមភ្លៀង។

៦៧. ស្លឱ្យសាប  អង្គុយឱ្យទាប  គំនិតឱ្យវែ  សម្តីឱ្យទន់។

៦៨. ស្លាប់ទុកដូចរស់  បានចំពោះដល់ជនណា  កាលរស់ខំធ្វើការ  ទុកជាកេរដល់អ្នកក្រោយ។

៦៩. បើស្អប់កុំឱ្យបាញ់  បើស្រលាញ់កុំឱ្យខ្ទី។

៧០. ស្អប់អ្នកដែលស្រលាញ់ខ្លួន  សពីក្បួនតម្រាច្បាប់  ចាស់ទុំលោកប្រៀងប្រាប់  ថាដូចចាប់ឆ្នាំងបាយបោក។

៧១. ហុចអំបោះ ស្រណោះដៃ (ឱ្យអ្វីៗមាននំចំណីជាដើមទៅអ្នកដទៃ ដោយមានសង្ឃឹមថាគេនឹងឲ្យអ្វីៗតបមកវិញពុំខាន
គឺឱ្យដោយសម្លឹងប្រយោជន៍ភ្លាមៗ)។

៧២. ហោរាចេះគ្នាន់គ្នេរ  ទាយឱ្យគេមានកំណើត  ទាយខ្លួនឯងមិនកើត  នៅតែក្រស៊ីឈ្នួលទាយ។

៧៣. អង្គុយហួសស័ក្តិ ស្រដីហួសថ្នាក់ បង់បោយហួសស្មា ពុំមើលប្រមាណនឹងប្រាណអាត្មា ហាហួសចង្កាអសារកាយេ។

៧៤. អាក្រក់ឬមួយល្អសឬមួយខ្មៅ រិធីក្នុងក្រៅត្រូវរិះឱ្យខ្វេច បើផ្លូវអាក្រក់យើងត្រូវចៀសគេច ផ្លូវល្អកុំភ្លេចត្រូវតែឱ្យជាប់។

៧៥. អាគកដូចអាចៃ មាន់ណាក៏ស៊ីស្រូវដែរ។

៧៦. អាចារ្យប្រែចិត្តជាអាចោរ ខ្លួនទំមែកពោធិស៊ីផ្លែជ្រៃ ទុច្ចរិតនាំខ្លួនឱ្យហីនហៃ អាស្រ័យសុចរិតកើតសុខា។

៧៧. អាវុធស្តេចស្រេចនៅឱង្ការ អាវុធសាមណាគឺសច្ចៈ អាវុធសេដ្ឋីគឺមាសប្រាក់ អាវុធអ្នកក្រគឺកម្លាំង។

៧៨. អាណិតអាវែក គេស៊ីក្រោមភ្នែក អាវែកមិនដឹង។

៧៩. អូសទូកកុំឱ្យល្អាន ចាប់ត្រីបានកុំឱ្យល្អក់ទឹក (ធ្វើការដែលមានរឿងទើសទាក់ឱ្យកើតបានដោយស្រួល កុំឱ្យមានផុរមោស់មោះហ្មង) គិតការទាំងឡាយឱ្យចេះនឹក ក្រែងមានគេដឹក(ឬអូស)បន្លាមកស្រាស់ផ្លូវ (អូសបន្លាស្រាស់ផ្លូវ = ជំទាស់មិនឱ្យកិច្ចការថ្មីកើតឡើងបាន)។

៨០. ចង់ឆាប់បែរឃើតណាស់ អូសសម្រាស់ប្រទះពាក្យ (អូសសម្រាស់ប្រទះពាក្យ = និយាយប៉ះពានទៅលើហេតុ លើរឿងនាំឱ្យទាស់ទាក់សម្តីគ្នា)។

៨១. អ្នកមានវិជ្ជាចេះលើសលប់ ប៉ុន្តែបើគ្មានគេរាប់អាន លើកតម្កើងក្នុងទីស្ថាន ក៏ពុំបានជាគាប់ល្អ។

៨២. ឱ្យចងឱ្យចាំទំនៀមព្រេង ឱ្យចេះឱ្យចែងកបបរិយាយ ឱ្យរាប់ព្រាងលានញាតិជិតឆ្ងាយ ក្តីល្អនឹងសាយមកផ្តុំផ្តោត។
ឱ្យចេះត្រង់ណាឱ្យមាំមួន ឱ្យចេះចាំក្បួនតម្រាសោត ឱ្យពេញជាប្រាជ្ញឱ្យគេកោត ឱ្យមានឫកសោតសមបទបាទ។

៨៣. ឱ្យរៀនរិះគិតពាក្យជូនតា ឱ្យរៀនវិជ្ជាសិល្បសាស្ត្រស្អាត ឱ្យរៀនចិត្តធ្ងន់កុំប្រមាថ ឱ្យខំសង្វាតរកទ្រព្យធន។
ឱ្យរៀនតម្រាសណ្តាប់ធ្នាប់ ឱ្យខំរកទ្រព្យកុំលួចប្លន់ ឱ្យសង្គ្រោះញាតិមានអាសន្ន នោះទើបពេញគុណជាអ្នកគាប់។

៨៤. ឱ្យមានមេត្តាប្រយ័ត្នទោស ឱ្យខំសន្តោសលស់វេរា ឱ្យមានមេត្រីប្រណីគ្នា ឱ្យជាប់ឱ្យជានូវខន្តី។
ឱ្យស្គាល់ខ្ពស់ទាបដរាបទៅ ឱ្យស្គាល់ប្រាជ្ញខ្លៅស្គាល់លោកិយ ឱ្យខ្លីមភាពថោកភាពក្រក្រី
ទើបស្គាល់ភាពថ្លៃភាពមានបាន។

៨៥. អ្នកដែលព្រហើនភ្លើនប៉ោងកោង ក្រអោងក្រអឺតឡឹតហួសខ្នាត តែងថយស័ក្តិយសរលស់ខាត ព្រោះចិត្តឧត្បាតប្រមាថគេ។

៨៦. អ្នកឥតធនធាន ចបើងចង់ថ្កាន ចង់ខ្ពស់លើសលែង ជនឥតកម្លាំង ចង់តាំងប្រលែង ចំប៉ាប់ទាត់ប៉ែងតែងនាំវិនាស។

៨៧. កុំលាបគ្រឿងសុគន្ធពាក់មាលា ស្លៀកភូសាអង្គាឱ្យលើសលែង កុំសម្អាងយ៉ាងយសព្រះគម្លែង អញ្ជើញតែងឱ្យសមនឹងសភាពខ្លួន។

៨៨. អំពៅមានរសផ្អែមប្រពៃ ផ្អែមវាចាស្រីលើសអំពៅ សុភាសិតបណ្ឌិតពោលប្រដៅ ផ្អែមលើសអំពៅនិងស្រីល្អ។

៨៩. អាំងភ្លើងឱ្យអាំងពីខាងផ្ទៃ អាំងថ្ងៃឱ្យអាំងពីខាងខ្នង។

៩០. អ្នកមានមិនដែលលើសបីតំណ អ្នកក្រមិនដែលលើសបីជាតិ។

៩១. អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន។
អ្នកខ្ពស់រក្សាទាប ដោយសភាពធម៌បុរាណ អ្នកឆ្អែតរក្សាឃ្លាន នោះទើបបានសុខរួមគ្នា។

៩២. ជនឥតប្រាជ្ញា ល្មោភថ្លែងវាចា ប្រាថ្នាអាងអួត នឹងត្រូវគេស្អប់ គេទុកស្មើឆ្កួត ព្រោះឡើងអំនួត ល្មោភអួតហួសមាឌ។

៩៣. អ្នកមុនកម្សោយ អ្នកក្រោយមានលាភ។

៩៤. អ្នកល្ងង់ត្រូវរៀនពីអ្នកចេះ ចង់បានចំណេះត្រូវស្តាប់គិត ចង់ទៅនិព្វានត្រូវហាត់ចិត្ត បើទីងងឹតត្រូវរកប្រទីប។

៩៥. អ្នកសប្បាយច្រើន ច្រើនមានទុក្ខ អ្នកប្រឹងលុយភក់ទើបផុតភ័យ សង្សារតាក់តែងតាមវិស័យ សុខទុក្ខបច្ច័យផ្លាស់វេនគ្នា។

៩៦. អ្នកធំកុំប្រមាថអ្នកតូច ស្មៅវល្លិវេញគួចចងដំរី ស្តេចពឹងលើរាស្ត្រទាំងប្រុសស្រី ទូកធំម្តេចក្តីតោងពឹងទឹក។

៩៧. អ្នកស្លូតស្អប់អ្នកកាច ពាលស្អប់ប្រាជ្ញពុំសូវខាន អ្នកក្រស្អប់អ្នកមាន រីអ្នកហ៊ានអ្នកខ្លាចស្អប់។

៩៨. អ្នកមានទ្រព្យ មិនខ្វះមិត្រភ្ញា ចុះចូលរាប់អាន រីអ្នកកំសត់ ក្រខ្សត់ធនធាន ញាតិមិត្រក៏ឈាន ចៀសពុំចង់បៀត។

៩៩. អ្នកដែលធ្វើការចង់រហ័ស រមែងតែងផ្លាស់ធ្វើច្រើនដង ព្រោះធ្វើមុនខុសធ្វើក្រោយសង ដល់ធ្វើច្រើនដងទៅជាយឺត។

១០០. អ្នកអួតខ្លួនថាបរិសុទ្ធ អ្នកនោះប្រាកដជាសៅហ្មង អ្នកអួតខ្លួនថាចេះចម្បង ប្រាកដតែម្តងគឺល្ងង់ខ្លៅ។